ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

# ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

# MINISTRY OF INDUSTRY, SCIENCE, TECHNOLOGY & INNOVATION

# ព្រឹត្តិបត្រផ្លូវការ

# OFFICIAL GAZETTE

# គំនូរឧស្សាហកម្ម

# INDUSTRIAL DESIGN

Volume 03, 2023

**អគ្គនាយកឧស្សាហកម្ម**

**General Department of Industry**

**នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម**

**Department of Industrial Property**

# ការស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម

# នៅកម្ពុជា

# Application for Registration of Industrial Design in Cambodia

# ព្រឹត្តិបត្រផ្លូវការ

**មាតិការ**


| | ទំព័រ |
|---|---|
| ១- ព័ត៌មានទូទៅ និងកំណត់សំគាល់ | ១ |
| ២- កំណត់សំគាល់ | ៣ |
| ៣- គំនូរឧស្សាហកម្ម ដែលបានចុះបញ្ជី | ៤ |

# ១-ព័ត៌មានទូទៅ និងកំណត់សំគាល់

**យោងតាមមាត្រា ១១៩ នៃច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម** ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានតួនាទីចុះផ្សាយនៅក្នុងព្រឹត្តិបត្រផ្លូវការរាល់គំនូរឧស្សាហកម្ម ដែលបានចុះបញ្ជីរួច។

**១-ព្រឹត្តិបត្រផ្លូវការ**

ព្រឹត្តិបត្រនេះត្រូវបានបោះពុម្ពដោយ នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម នៃអគ្គនាយកដ្ឋានឧស្សាហកម្ម ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដោយ **អនុលោមតាមប្រការ ២៥ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម។**

ព្រឹត្តិបត្រផ្លូវការនេះ អាចរកបាននៅលើវេបសាយនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម (https://dip.misti.gov.kh/)។

**២-ម៉ោងធ្វើការ**

ថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ ព្រឹក ម៉ោង ៨ ដល់ម៉ោង ១១:៣០

ល្ងាច ម៉ោង ១៤ ដល់ម៉ោង ១៧:៣០

ថ្ងៃសៅរ៍ និង ថ្ងៃអាទិត្យ សម្រាក

**៣-ការសួរព័ត៌មាន**

សម្រាប់ការសួរព័ត៌មានទាក់ទងទៅនឹងបញ្ហាផ្សេងៗ ដែលមាននៅក្នុងព្រឹត្តិបត្រផ្លូវការនេះ សូមទំនាក់ទំនង៖

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

អាសយដ្ឋាន: លេខ ៤៥ ព្រះនរោត្តម ខណ្ឌ ដូនពេញ ភ្នំពេញ

**៤-គោលការណ៍មួយចំនួនស្តីពីគំនូរតំណាងនៃគំនូរឧស្សាហកម្ម**

គំនូរតំណាងសម្រាប់គំនូរឧស្សាហកម្ម ដែលបានដាក់ស្នើ សម្រាប់គំនូរឧស្សាហកម្ម ដែលស្វែងរកការការពារត្រូវច្បាស់លាស់ និងមានគុណភាពល្អ។ កត្តានេះសំខាន់ណាស់ពីព្រោះរូបតំណាងមួយ មិនច្បាស់លាស់ មានគុណភាពអន់មិនអាចបញ្ជាក់ច្បាស់លាស់នូវកន្លែងដែលចង់ការពារ។ ដូចនេះការិយាល័យគំនូរឧស្សាហកម្ម ទាមទារយ៉ាងខ្លាំងនូវគំនូរតំណាងមួយ ដែលច្បាស់លាស់ និងគុណភាពខ្ពស់។

**៥-គំនូរបង្ហាញគំនូរឧស្សាហកម្ម**

យោងតាមប្រការ ៦ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម តម្រូវឲ្យ៖

១-ក្រាហ្វិចតាង/គំនូសបង្ហាញ/គំនូសផ្ទាប់ចម្លងតាម/រូបថត

-ចំនួន ០៤ ច្បាប់ ប្រសិនបើគំនូរឧស្សាហកម្មជាទំរង់ ពីរខ្នាត និង

-ផ្នែកខុសៗគ្នានីមួយៗរបស់គំនូរឧស្សាហកម្ម ចំនួន ០៤ ច្បាប់ ប្រសិនបើគំនូរឧស្សាហកម្ម ជាទំរង់បីខ្នាត។

-គំនូរឧស្សាហកម្មមិនត្រូវមានខ្នាតធំលើសពីទំហំ ១០ស.ម X ២០ស.ម ឡើយ។

២-ក្រដាស

គំនូរឧស្សាហកម្ម ត្រូវគូសនៅលើក្រដាសរឹង ដែលមន ទំហំ A4។

៣-រូបថត

រូបថត ត្រូវថតគ្រប់ផ្នែកនីមួយៗ នៃគំនូរឧស្សាហកម្ម និងមានផ្ទាំងខាងក្រោយពណ៌ស។

**៦-សុពលភាព នៃការបរិច្ឆេទអាទិភាព**

យោងតាមមាត្រា ២៧, មាត្រា ២៨ និងមាត្រា ២៩ នៃច្បាប់ស្តីពីក្រាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងចុះបញ្ជីគំនូរឧស្សាហកម្ម ចំពោះសិទ្ធិអាទិភាពនៃសុំណុំលិខិតស្នើសុំ ដែលបានចុះបញ្ជីមុនគេ ដោយអ្នកដាក់ពាក្យសុំ ឬដោយអ្នកស្នងជំនួសឲ្យបុព្វជនរបស់ពួកគេ នៅក្នុងប្រទេសមួយ ឬច្រើនដែលប្រទេសទាំងនោះ ជាសមាជិកអនុសញ្ញាទីក្រុងប៉ារីស ឬអង្គការ ពាណិជ្ជកម្មពិភពលោក មានសុពលភាព ៦ខែ ចាប់ពីកាលបរិច្ឆេទចុះបញ្ជី នៅប្រទេសដែលបានដាក់ពាក្យស្នើសុំដំបូង។

**៧-រយៈពេលការការពារគំនូរ**

យោងតាមមាត្រា ១០៩ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងចុះបញ្ជីគំនូរឧស្សាហកម្ម ចំពោះការចុះបញ្ជីគំនូរឧស្សាហកម្មមានរយៈពេល ៥ឆ្នាំ ចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំ។ ការចុះបញ្ជីអាចធ្វើសាឡើងវិញបានចំនួនពីរ (២) ដងជាប់ៗគ្នា ដែលម្តងៗមានសុពលភាពប្រាំ (៥)ឆ្នាំ **សរុប រយៈពេលផ្តល់ការការពារទាំងអស់ ១៥ (ដប់ប្រាំ)ឆ្នាំ។**

**៨-ការបោះពុម្ពផ្សាយព្រឹត្តិបត្រផ្លូវការ**

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម និងបោះពុម្ពផ្សាយនូវព្រឹត្តិបត្រផ្លូវការ នៅថ្ងៃទី១ ដើមខែ រៀងរាល់ខែ។ នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម មានសិទ្ធិគ្រប់គ្រាន់ក្នុងការពន្យាពេលបោះពុម្ពផ្សាយ ក្នុងករណីចាំបាច់។

# កំណត់សំគាល់

# Notice

(១)-កាលបរិច្ឆេទទទួលពាក្យសុំ — (1)-Receiving date

(២)-កាលបរិច្ឆេទចុះបញ្ជី — (2)-Filling date

(៣)-កាលបរិច្ឆេទអាទិភាព — (3)- Priority date

(៤)-កាលបរិច្ឆេទផ្តល់វិញ្ញាបនបត្រ — (4)-Registration date

(៥)- កាលបរិច្ឆេទផុតកំណត់ — (5)-Expiration date

(៦)-អ្នកដាក់ពាក្យសុំ — (6)-Applicants

(៧)-លេខគំនូរឧស្សាហកម្ម — (7)-Industrial Design number

(៨)-ចំណាត់ថ្នាក់គំនូរឧស្សាហកម្ម — (8)- Classification

(៩)-ប្រទេសដែលត្រូវបានប្រកាសអាទិភាព — (9)-Priority-claimed Country

(១០)-ឈ្មោះគំនូរឧស្សាហកម្ម — (10)-Title of Industrial Design

(១១)-ប្រភេទផលិតផលដែលប្រើចំពោះគំនូរឧស្សាហកម្ម — (11)-The product is to be used for Industrial Design.

# ២-គំនូរឧស្សាហកម្មដែលបានចុះបញ្ជី

| | | | |
|---|---|---|---|
| ១- | ថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៣ | 1- | 8 August, 2023 |
| ២- | ថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៣ | 2- | 8 August, 2023 |
| ៣- | No Priority Claimed | 3- | No Priority Claimed |
| ៤- | ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ | 4- | 6 September, 2023 |
| ៥- | ថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៨ | 5- | 8 August, 2028 |
| ៦- | ឡេង ស្រ៊ុយហៀង<br>ផ្ទះលេខ ៤៩AE0E1 ផ្លូវ១៣៤ ភូមិ៥ សង្កាត់ផ្សារដេប៉ូ២<br>ខណ្ឌទួលគោក ភ្នំពេញ Cambodia | 6- | ឡេង ស្រ៊ុយហៀង<br>ផ្ទះលេខ ៤៩AE0E1 ផ្លូវ១៣៤ ភូមិ៥ សង្កាត់ផ្សារដេប៉ូ២<br>ខណ្ឌទួលគោក ភ្នំពេញ Cambodia |
| ៧- | កដ/គឧ/២០២៣/០០០៤៦ | 7- | KH/ID/2023/00046 |
| ៨- | ០៩-០១ | 8- | 09-01 |
| ៩- | No Priority Claimed | 9- | No Priority Claimed |
| ១០- | ដប | 10- | Bottle |
| ១១- | ដប | 11- | Bottle |

